ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១១ សរណន

# សារាចរណែនាំ
# ស្តីពី
# ការបញ្ជូនគណៈប្រតិភូទៅបំពេញបេសកកម្មនៅបរទេស

កន្លងមករាជរដ្ឋាភិបាលបានសង្កេតឃើញថា គ្រប់ក្រសួង ស្ថាប័ន បានដំណើរការចូលរួមអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលយ៉ាងមម៉ាញឹក ក្នុងនោះមានការបញ្ជូនគណៈប្រតិភូ ទៅបំពេញទស្សនកិច្ច ចូលរួមសន្និសីទ កិច្ចប្រជុំអន្តរជាតិនានា ទៅបរទេសជាបន្តបន្ទាប់។ ប៉ុន្តែមានក្រសួង ស្ថាប័នមួយចំនួន បានបញ្ជូនគណៈប្រតិភូទៅបំពេញបេសកកម្មនៅបរទេស ពុំបានជូនព័ត៌មានឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាងស្ថានទូតកម្ពុជា ប្រចាំនៅបរទេសចូលរួមនៅក្នុងសកម្មភាពជាមួយគណៈប្រតិភូ ឬ ដើម្បីសម្របសម្រួល និងតាមដានរាល់កិច្ចសហប្រតិបត្តិការ និង ទំនាក់ទំនងជាមួយបណ្តាប្រទេសនោះនៅឡើយ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលសូមណែនាំដល់គ្រប់ក្រសួង ស្ថាប័នថា ចាប់ពីពេលនេះតទៅ សូមឱ្យក្រសួង ស្ថាប័នរដ្ឋ ដែលបញ្ជូនគណៈប្រតិភូទៅបំពេញបេសកកម្មនៅបរទេស ត្រូវផ្តល់ព័ត៌មានជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិឱ្យបានមុន ដើម្បីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានលទ្ធភាពជូនដំណឹង ឬចាត់ឱ្យស្ថានទូតកម្ពុជា ជួយសម្រួលបេសកកម្មរបស់គណៈប្រតិភូផង និងចូលរួមក្នុងសកម្មភាពនានារបស់គណៈប្រតិភូផង។ ក្រោយពេលបំពេញបេសកកម្ម គណៈប្រតិភូគ្រប់ក្រសួង ស្ថាប័នរដ្ឋ ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋបាល និងចម្លងជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីក្រសួងការបរទេស និងសហប្រតិការអន្តរជាតិ មានលទ្ធភាពបន្តតាមដានការងារទាំងនោះជាបន្តទៀត។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចាត់ឯកអគ្គរាជទូត ឬតំណាងស្ថានទូតឱ្យចូលរួមទៅតាមកម្រិតគណៈប្រតិភូនីមួយៗ។

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

ចំពោះរាល់ទស្សនកិច្ចនៅបរទេសរបស់ថ្នាក់ដឹកនាំនៃគ្រប់ក្រសួងស្ថាប័ន ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ ត្រូវសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលជាមុនសិន។

ទទួលបានសារាចរណែនាំនេះ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិកាគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមខ្លឹម-សារលើនេះឱ្យបានសម្រេចលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង និងស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ